ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៣៥១
ចុះថ្ងៃទី០១-៤-២០១៤
សាលដីកា
លេខ: ៥៥ ក្រVI.ប
ចុះថ្ងៃទី២៩-៧-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី២៥-៧-២០១៤ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងសុំស្រូបទោសបញ្ចូលគ្នា នៃរឿងព្រហ្មទណ្ឌលេខ ៣៥១ ចុះថ្ងៃទី០១-៤-២០១៤ រវាង:

- ទណ្ឌិតឈ្មោះ [redacted] ស៊ីណាត ហៅ [redacted] សារុជ ភេទប្រុស អាយុ៤៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ [redacted] ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ទោសពីមុន គ្មាន ឃុំខ្លួន នៅថ្ងៃទី៣០-៣-២០១១ នៅពន្ធនាគារ ម១ ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី២៥-០២-២០១៤ របស់ទណ្ឌិតឈ្មោះ [redacted] ស៊ីណាត ដោយមានការបញ្ជាក់ពីប្រធានមណ្ឌលអប់រំកែប្រែ ម១ បានដាក់ពាក្យបណ្តឹងគោរពចូលមកឯកឧត្តមប្រធានសាលាឧទ្ធរណ៍ សំណើសុំស្រូបទោសបញ្ចូលគ្នា ចំពោះសំណុំរឿងរបស់ខ្លួនចំនួន ០២រឿង: គឺទី១ សំណុំរឿងព្រហ្មទណ្ឌលេខ ៨១៧ ចុះថ្ងៃទី០៩-៩-២០១១ របស់សាលាឧទ្ធរណ៍ និងទី២ គឺសំណុំរឿងព្រហ្មទណ្ឌលេខ ៨១៦ ចុះថ្ងៃទី០៩-៩-២០១១ របស់សាលាឧទ្ធរណ៍ ។



៤៦៧

**សំណុំរឿងទី០១**

សំណុំរឿងព្រហ្មទណ្ឌលេខ ៨១៧ ចុះថ្ងៃទី០៩-៩-២០១១

របស់សាលាឧទ្ធរណ៍

- ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត ហៅ [redacted] សាវុធ ភេទប្រុស អាយុ៤៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ [redacted] ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ទោសពីមុន គ្មាន ឃុំខ្លួន នៅថ្ងៃទី៣០-៣-២០១១ នៅពន្ធនាគារ ម១ ។

ត្រូវជាប់ចោទពីបទ: ប្លន់ (លួចមានគ្នាច្រើន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ១០-១២-២០០០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិ [redacted] ។

**៦រឿងហេតុមានដូចតទៅ:**

តាមកំណត់ហេតុបណ្តឹង ចុះថ្ងៃទី១០-១២-២០០០ របស់នគរបាលប៉ុស្តិ៍ច្រាំងចំរេះ២ ដែលមានជនរងគ្រោះឈ្មោះ [redacted] សុខហៀង ប្តឹងថា កាលពីថ្ងៃទី១០-១២-២០០០ វេលាម៉ោង ២.០០ទៀបភ្លឺ មានចោរលួចគាស់ផ្ទះយកម៉ូតូ ០១គ្រឿង ម៉ាកសេ ១០០កូវ៉េ ពណ៌ក្រហម ពាក់ស្លាកលេខ ផ2002 លេខតួ CT100F 1276703 លេខម៉ាស៊ីន CT 100 9276652 យកទៅបាត់ ទើបខ្លួនប្តឹងសុំឲ្យសមត្ថកិច្ចជួយស្រាវជ្រាវចាប់ជនល្មើសយកមកផ្តន្ទាទោសតាមផ្លូវច្បាប់ដោយសេចក្តីអនុគ្រោះផង ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៨ (ដ) ចុះថ្ងៃទី០៧-៣-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា:

១- ផ្តន្ទាទោសឈ្មោះ [redacted] ឃឿន ភេទប្រុស អាយុ២៥ឆ្នាំ និងឈ្មោះ [redacted] ណា ហៅ អួក ភេទប្រុស អាយុ៣៥ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗកំណត់ចំនួន ០៤(បួន)ឆ្នាំ គិតបន្តពីសាលក្រមមុន ពីបទ: ប្លន់ (លួចមានគ្នាច្រើន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១០-១២-២០០០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២- ផ្តន្ទាទោសឈ្មោះ [redacted] ស៊ីណាត ភេទប្រុស អាយុ៣៩ឆ្នាំ និងឈ្មោះ [redacted] ជឿន ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗកំណត់ចំនួន ០៤ (បួន)ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនបាន ពីបទ: ប្លន់ (លួចមានគ្នាច្រើន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១០-១២-២០០០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។



៤៦៥

៣- សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឃឿន និងឈ្មោះ [redacted] ណា ហៅ អ្នក កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត, [redacted] ឃឿន និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៧៦ ក្រ៦ (ន) ចុះថ្ងៃទី៣០-៦-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា:

១- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៨ (ដ) ចុះថ្ងៃទី០៧-៣-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូលដដែល ។

២- ទុកសិទ្ធិឲ្យដើមបណ្តឹងឈ្មោះ [redacted] ប្តឹងទាមទារសំណងនៅពេលក្រោយ។

៣- សាលក្រមនេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៧-៦-២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០-៦-២០១១ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៣១ ក្រ៦ (វ) ចុះថ្ងៃទី១៣-៧-២០១២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា:

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥-៧-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៧៦ ក្រ៦ (ន) ចុះថ្ងៃទី៣០-៦-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ដោយគ្រាន់តែកែប្រែសាលក្រមព្រហ្មទណ្ឌលេខ ១៨(ដ) ចុះថ្ងៃទី០៧-៣-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច ទី២ ដូចតទៅ:

ក - កែប្រែបទចោទពីបទ: ប្លន់ (លួចមានគ្នាច្រើន) ទៅជា បទ: លួច ដែលជាបទល្មើស មានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

ខ- ផ្តន្ទាទោសលើឈ្មោះ [redacted] ស៊ីណាត ដាក់ពន្ធនាគារកំណត់ ១៨ (ដប់ប្រាំបី)ខែ ពីបទ: លួច ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១០-១២-២០០០ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

- ចំណុចផ្សេងពីនេះរក្សាទុកដដែល ។

៣- បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត តាមនីតិវិធី ។

៤- សាលដីកានេះ ប្រកាសជាសាធារណៈ ថ្ងៃទី១៣-៧-២០១២ ចំពោះមុខជនជាប់ចោទ។

- បើកសិទ្ធប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

សាលដីកានេះបានចូលជាស្ថាពរហើយ ។



៤៦៨

**សំណុំរឿងទី០២**

សំណុំរឿងព្រហ្មទណ្ឌលេខ ៨១៦ ចុះថ្ងៃទី០៩-៩-២០១១

របស់សាលាឧទ្ធរណ៍

- ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត ហៅ [redacted] សាវុធ ភេទប្រុស អាយុ៤៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ [redacted] ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ទោសពីមុនគ្មាន ឃុំខ្លួន នៅថ្ងៃទី៣០-៣-២០១១ នៅពន្ធនាគារ ម១ ។

ត្រូវជាប់ចោទពីបទៈ ប្លន់ (លួចមានគ្នាច្រើន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣-៨-២០០០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិ [redacted]

**<u>៦រឿងហេតុមានដូចតទៅៈ</u>**

តាមពាក្យបណ្ដឹង ចុះថ្ងៃទី១៣-៨-២០០០ របស់ឈ្មោះ [redacted] សៀក បញ្ជាក់ថា កាលពីថ្ងៃទី ១៣-៨-២០០០ វេលាម៉ោង ៣.០០ទៀបភ្លឺ មានចោរចូលលួចគាស់ផ្ទះយកម៉ូតូ ០១គ្រឿង ម៉ាកសាន់យ៉ាន់ ពណ៌ស្លាបក្អែក លេខតួគ្មាន លេខម៉ាស៊ីន 127420 គ្មានស្លាកលេខយកទៅបាត់ ទើបខ្លួនប្ដឹងសុំឲ្យសមត្ថកិច្ចជួយស្រាវជ្រាវរកចាប់ជនល្មើសយកមកផ្ដន្ទាទោសតាមផ្លូវច្បាប់ ដោយសេចក្ដីអនុគ្រោះផង ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៩ (ដ) ចុះថ្ងៃទី០៧-៣-២០០៧ របស់សាលា ដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចថាៈ

១- ផ្ដន្ទាទោសឈ្មោះ [redacted] ឃឿន ភេទប្រុស អាយុ២៥ឆ្នាំ និងឈ្មោះ [redacted] ណា ហៅ អូក ភេទប្រុស អាយុ៣៥ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗកំណត់ចំនួន ០៤ (បួន)ឆ្នាំ គិតបន្តពីសាលក្រមមុន ពីបទៈ ប្លន់(លួចមានគ្នាច្រើន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៣-៨-២០០០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- ផ្ដន្ទាទោសឈ្មោះ [redacted] ស៊ីណាត ភេទប្រុស អាយុ៣៩ឆ្នាំ និងឈ្មោះ [redacted] ឌឿន ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗកំណត់ចំនួន ០៤ (បួន)ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនបាន ពីបទៈ ប្លន់(លួចមានគ្នាច្រើន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៣-៨-២០០០ បទល្មើស ព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣- សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឃឿន និងឈ្មោះ [redacted] ណា ហៅ អូក កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត, [redacted] ជឿន និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៧៥ ក្រ៦ (ន) ចុះថ្ងៃទី៣០-៦-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចថា:

១- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៩ (ដ) ចុះថ្ងៃទី០៧-៣-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូលដដែល ។

២- ទុកសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សៀក ប្ដឹងទាមទារសំណងនៅពេលក្រោយ ។

៣- សាលក្រមនេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៧-៣-២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០-៦-២០១១ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៣០ ក្រ៦ (វ) ចុះថ្ងៃទី១៣-៧-២០១២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចថា:

១- ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥-៧-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត ទុកជាត្រឹមត្រូវ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៧៥ ក្រ៦ (ន) ចុះថ្ងៃទី៣០-៦-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ដោយគ្រាន់តែកែប្រែសាលក្រមព្រហ្មទណ្ឌលេខ ១៩(ដ) ចុះថ្ងៃទី០៧-៣-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចផ្ដន្ទាទោសលើឈ្មោះ [redacted] ស៊ីណាត ដាក់ពន្ធនាគារកំណត់ ០៣(បី)ឆ្នាំ វិញ ។ ចំណុចផ្សេងពីនេះរក្សាទុកដដែល ។

៣- បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត តាមនីតិវិធី ។

៤- សាលដីកានេះ ប្រកាសជាសាធារណៈ ថ្ងៃទី១៣-៧-២០១២ ចំពោះមុខជនជាប់ចោទ។

- បើកសិទ្ធិប្ដឹងតវ៉ាក្នុងកំណត់ច្បាប់ ។

សាលដីកានេះបានចូលជាស្ថាពរហើយ ។

- បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី០៦-៦-២០១៤ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

- បានឃើញ សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី២១-៧-២០១៤ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## <u>នាពេលសវនាការ</u>

- ទណ្ឌិតឈ្មោះ [redacted] ស៊ីណាត (វត្តមាន)
- មានមេធាវីការពារសិទ្ធិឲ្យទណ្ឌិត លោក [redacted] លី (វត្តមាន)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

- ទណ្ឌិតឈ្មោះ [redacted] ស៊ីណាត បានឆ្លើយថា ខ្លួនជាប់ពន្ធនាគារបាន ៣ឆ្នាំ ៣ខែ ២៥ថ្ងៃហើយ ។ សំណូមពរ សុំឲ្យតុលាការស្រូបទោសរបស់ខ្លួនបញ្ចូលគ្នា ។

## <u>តំណាងមហាអយ្យការសន្និដ្ឋានថា:</u>

ការសុំស្រូបទោសមានលក្ខណៈត្រឹមត្រូវហើយ យោងតាមមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ ។ ហេតុនេះសូមក្រុមប្រឹក្សាពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។

## <u>មេធាវីការពារសិទ្ធិឲ្យទណ្ឌិតសន្និដ្ឋាន:</u>

- លោក [redacted] លី មេធាវីការពារសិទ្ធិឲ្យទណ្ឌិតសន្និដ្ឋានថា ក្រោយពីកូនក្តីខ្លួនជាប់ពន្ធនាគារបាន ៣ឆ្នាំ ៣ខែ ២៥ថ្ងៃ ហើយបានកែប្រែខ្លួនតាមលិខិតបញ្ជាក់អំពីកិរិយាមាយាទពីមណ្ឌលកែប្រែ-អប់រំ ចុះថ្ងៃទី១៦-៧-២០១៤ ផងដែរ ។ ដូច្នេះ សំណូមពរ សុំក្រុមប្រឹក្សាមេត្តាស្រូបទោសឲ្យកូនក្តីខ្លួន ។
- ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង
- ក្រោយពីបានស្តាប់ចម្លើយរបស់ទណ្ឌិត
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យទណ្ឌិត
- ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សាលាឧទ្ធរណ៍យល់ឃើញថា:</u>

១- បណ្តឹងសុំស្រូបទោស ចុះថ្ងៃទី២៥-០២-២០១៤ របស់ទណ្ឌិតឈ្មោះ [redacted] ស៊ីណាត បណ្តឹងនេះធ្វើឡើងក្នុងត្រឹមត្រូវតាមច្បាប់ យោងតាមមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចជំនុំជម្រះបាន ។

២- ទណ្ឌិតឈ្មោះ [redacted] ស៊ីណាត មានសាលដីកាស្ថាពរចំនួនពីរៈ

- សាលដីកាព្រហ្មទណ្ឌលេខ ៣១ ក្រ៦ (វ) ចុះថ្ងៃទី១៣-៧-២០១២ របស់សាលាឧទ្ធរណ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល ១៨ខែ ។
- សាលដីកាព្រហ្មទណ្ឌលេខ ៣០ ក្រ៦ (វ) ចុះថ្ងៃទី១៣-៧-២០១២ របស់សាលាឧទ្ធរណ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល ៣ឆ្នាំ ។

៣- នៅចំពោះមុខសាលាឧទ្ធរណ៍ ទណ្ឌិតឈ្មោះ [redacted] ស៊ីណាត បានឆ្លើយបញ្ជាក់ថា តាមរយៈសាលដីកាស្ថាពរទាំងពីរខាងលើនោះខ្លួនទទួលរងទណ្ឌកម្មនៅក្នុងពន្ធនាគារ ៤



៤៧៦២

អស់រយៈពេល ៣ឆ្នាំ ៣ខែ ២៥ថ្ងៃ មកហើយ ខ្លួនបានកែប្រែខ្លួន រៀនសូត្រចេះដឹងច្រើន មានបំណងចូលរួមធ្វើសកម្មភាពជាពលរដ្ឋល្អក្នុងសង្គម ។

៤- ទណ្ឌិតឈ្មោះ [redacted] ស៊ីណាត មានលិខិតបញ្ជាក់អំពីកិរិយាមាយាទពីមណ្ឌលកែប្រែ-អប់រំ ចុះថ្ងៃទី១៦-៧-២០១៤ រួមទាំងការលើកឡើងរបស់សាមីខ្លួនទណ្ឌិត គប្បីសាលាឧទ្ធរណ៍លើកមកពិចារណាស្រាលទោសពន្ធនាគារ ដែលប្រកាសលើឈ្មោះ [redacted] ស៊ីណាត ១៨ខែ នៃសាលដីកាព្រហ្មទណ្ឌលេខ ៣១ ក្រ៦ (រ) ចុះថ្ងៃទី១៣-៧-២០១២ របស់សាលាឧទ្ធរណ៍ ទៅក្នុងទោសដែលប្រកាសលើឈ្មោះ [redacted] ស៊ីណាត ក្នុងសាលដីកាព្រហ្មទណ្ឌលេខ ៣០ ក្រ៦ (រ) ចុះថ្ងៃទី១៣-៧-២០១២ របស់សាលាឧទ្ធរណ៍ តាមការស្នើសុំ

**ហេតុដូច្នេះ**

**ទនិច្ឆ័យសេចក្តី:**

១- ទទួលពាក្យបណ្តឹងសុំស្រាលទោស ចុះថ្ងៃទី២៥-០២-២០១៤ របស់ទណ្ឌិតឈ្មោះ [redacted] ស៊ីណាត ទុកជាត្រឹមត្រូវតាមច្បាប់ ។

២- ឲ្យស្រាលទោសពន្ធនាគារ ដែលប្រកាសលើទណ្ឌិតឈ្មោះ [redacted] ស៊ីណាត ១៨ខែ ក្នុងសាលដីកាព្រហ្មទណ្ឌលេខ ៣១ ក្រ៦ (រ) ចុះថ្ងៃទី១៣-៧-២០១២ របស់សាលាឧទ្ធរណ៍ ទៅក្នុងទោស ៣ឆ្នាំ ក្នុងសាលដីកាព្រហ្មទណ្ឌលេខ ៣០ ក្រ៦ (រ) ចុះថ្ងៃទី១៣-៧-២០១២ របស់សាលាឧទ្ធរណ៍ ។

៣- ទោសត្រូវអនុវត្ត គឺ ៣ឆ្នាំ ៦ខែ ។

៤- សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៥-៧-២០១៤ ចំពោះមុខទណ្ឌិតឈ្មោះ [redacted] ស៊ីណាត និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទលោក [redacted]បី ប្រកាសជាសាធារណៈ នៅថ្ងៃទី២៩-៧-២០១៤ ។

- បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយ សហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី...២០...ខែសីហា...ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]



៤៧៣